ឆ្នាំ ទី ៦ លេខ ៩០ សប្តាហ៍ ទី ១ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៦ រាជកិច្ច ទំព័រ ៧៩២៩

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការឈប់ទទួលស្គាល់វិទ្យាស្ថាន អន្តរជាតិ អេស អាយ ធី ស៊ី

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**មាត្រា ១.-**

បញ្ឈប់ការទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី SITC International Institute ហៅកាត់ជាភាសាខ្មែរ វ.អ.អ.ធ.ស និងហៅកាត់ជាភាសាអង់គ្លេស S.I.I ដែលមានទីតាំងស្ថិតនៅ អគារលេខ ៣១៥ ផ្លូវហ្សាល ដឺហ្គូល សង្កាត់អូឫស្សី ទី២ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ។

**មាត្រា ២.-**

វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី ត្រូវបញ្ឈប់ការបណ្តុះបណ្តាលគ្រប់កំរិត និងគ្រប់រូបភាពកិច្ចសហប្រតិបត្តិការ ជាមួយគ្រឹះស្ថានឧត្តមសិក្សា ក្នុង និងក្រៅប្រទេសនានា ។

**មាត្រា ៣.-**

ក្រោយពេលដែលបញ្ឈប់ការបណ្តុះបណ្តាល វិទ្យាស្ថានត្រូវតែចេញព្រឹត្តិបត្រពិន្ទុ ដល់និស្សិតទាំងអស់ដែលបានសិក្សានៅវិទ្យាស្ថានតាមកំរិត និងកម្មវិធីសិក្សា ដែលពួកគេបានសិក្សារួចហើយ ។

**មាត្រា ៤.-**

អនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៦

ហ៊ុន សែន

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ